ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　ជាតិ　សាសនា　ព្រះមហាក្សត្រ

សភាជំនុំរដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណី
លេខ ២៤　　　　　　តាំងនាមប្រជារាស្ត្រខ្មែរ
ចុះថ្ងៃទី១៥ខែធ្នូឆ្នាំ១៩៩៤

សាលដីកា　　　　　　តុលាការកំពូល

លេខ ១០១ ក.ស.

ចុះថ្ងៃទី១៧ខែមិថុនាឆ្នាំ១៩៩៥

បានបើកសវនាការ ជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៥ ដោយមាន - សមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | - | ឯកឧត្តម | ឌិត មុន្ទី | ប្រធាន |
| ២ | - | លោក | ប៉ិន ស៊ិន | ចៅក្រមរបាយការណ៍ |
| ៣ | - | លោក | ទេវុល មួន | ចៅក្រម |
| ៤ | - | លោក | ស៊ិន ឌឹម | ចៅក្រម |
| ៥ | - | លោក | ឌី កេង | ចៅក្រម |
| ៦ | - | លោក | ប្រាក់ ទឹមសាន | ចៅក្រម |
| ៧ | - | លោក | ឈឹម ស៊ីផុល | ចៅក្រម |
| ៨ | - | លោក | សោម សិរីវណ្ណ | ចៅក្រម |
| ៩ | - | លោក | យស់ សុខឿន | ចៅក្រម |

ក្រឡាបញ្ជី
លោក ទៀង វុន

តំណាងមហាអយ្យការ
លោក សាយ សារី　ជាព្រះរាជអាជ្ញា

ដើម្បី ជំនុំជំរះ លើបណ្តឹងសាទុក្ខលើសាលដីការដ្ឋប្បវេណីលេខ ៧៤ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៤ និង សំណុំរឿងរដ្ឋប្បវេណីលេខ ៨៦ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៤ របស់ - សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ឈួន វណ្ណា ភេទប្រុស អាយុ ៣៦ឆ្នាំ សញ្ជាតិកម្ពុជា របរកសី ធ្វើសិប្បកម្មផលិតនំ ទីលំនៅ ផ្ទះលេខ ១០៤ ផ្លូវលេខ ២៩៦ ក្រុម ៤៣ សង្កាត់ទួលស្វាយព្រៃ ១ ខណ្ឌ ចំការមន ក្រុងភ្នំពេញ កូនឈ្មោះ ឈួន ឈឹម " " ម្តាយឈ្មោះ អ៊ុន ង៉ា " " ។

និង ចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ កោះ ស៊ីវ៉ាត ភេទប្រុស អាយុ ៥៩ឆ្នាំ សញ្ជាតិ កម្ពុជា របរកសី ធ្វើការនៅសម្ព័ន្ធកម្ពុជា ទីលំនៅ ផ្ទះលេខ ១០៤ ផ្លូវលេខ ២៩៦ ក្រុមទី ៤៣ សង្កាត់ទួលស្វាយព្រៃទី ២ ខណ្ឌចំការមន ក្រុងភ្នំពេញ កូនឈ្មោះ កោះ យុន "ស"

ម្ដាយឈ្មោះ ហែម សាត់ " ម " ។

<u>កម្មវត្ថុបណ្ដឹង</u> : ប្ដឹងទាមទារមូលដ្ឋានសិប្បកម្មផលិតនំពីឈ្មោះ ឈួន វណ្ណា ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ១៥- ០៩- ៨៩ របស់ឈ្មោះ កោះ ស៊ីវ៉ាត ជាដើមចោទប្ដឹងសុំដកហូតមូលដ្ឋានសិប្បកម្មផលិតនំនៅផ្ទះលេខ ១០៤ ក្រុម៤៣ សង្កាត់ ទួលស្វាយព្រៃ ២ ពីឈ្មោះ ឈួន វណ្ណា ដោយមូលហេតុឈ្មោះ ឈួន វណ្ណា បានជួលផ្ទះខ្លួនធ្វើសិប្បកម្មផលិតនំ ចាប់តាំងពីថ្ងៃទី ០១- ០៨- ៨៤ និង ផុតកិច្ចសន្យាជួលនៅឆ្នាំ ១៩៨៨ ដោយអោយតំលៃជួលក្នុងមួយខែ ៥០០រៀល តែឈ្មោះនេះពុំបានអនុវត្តទៅតាមកិច្ចសន្យាទេ ថែមទាំងបង្កទំនាស់ និង មានបំណងយកផ្ទះដែលជួលនេះធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនទៀត ។ ខ្លួនសុំបញ្ជាក់ថាផ្ទះទាំងពីរល្វែងនេះខ្លួនបានមករស់នៅតាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១៣៣ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ១៩៩១ របស់ តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ១៥- ០៩- ១៩៨៩ របស់ដើមចោទឈ្មោះ - កោះ ស៊ីវ៉ាត ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។
២ - ទទួលស្គាល់កិច្ចសន្យាដោយផ្ទាល់មាត់រវាងឈ្មោះ យោន តេង , សាវ សុខ និង កោះ ស៊ីវ៉ាត ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។
៣ - ទទួលស្គាល់កិច្ចសន្យាចុះថ្ងៃទី ១៨- ១១- ៨៧ រវាងឈ្មោះ កោះ ស៊ីវ៉ាត និង ឈួន វណ្ណា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។
៤ - ប្រគល់មូលដ្ឋានសិប្បកម្មផលិតនំនៅផ្ទះលេខ ១០៤ ក្រុម ៤៣ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន ក្រុងភ្នំពេញ អោយទៅឈ្មោះ កោះ ស៊ីវ៉ាត កាន់កាប់ និង ប្រើប្រាស់ចាប់តាំងពីថ្ងៃប្រកាស សាលក្រមនេះតទៅ ។
៥ - អោយឈ្មោះ ឈួន វណ្ណា និង ក្រុមគ្រួសារ រុះរើសំភារៈ និង ចុះចេញពីផ្ទះលេខ ១០៤ ក្រុម ៤៣ សង្កាត់ ទួលស្វាយព្រៃ ២ ខណ្ឌចំការមន ក្រុងភ្នំពេញ ក្នុងរយៈពេល ២០ ថ្ងៃ ចាប់តាំងពីថ្ងៃប្រកាស សាលក្រម នេះតទៅ ។
៦ - សាលក្រមនេះ ប្រកាស ជាសាធារណៈ ចំពោះ មុខគូក្ដី សំរេចសាលើកទី ១ និង សាលើកចុងក្រោយបង្អស់ ។

បានឃើញ បណ្ដឹងតវ៉ារបស់ឈ្មោះ ឈួន វណ្ណា ចុះថ្ងៃទី ០៥- ៩- ៩១ មក តុលាការប្រជាជនកំពូល ។

បានឃើញ ដីកាផ្អាកជាបណ្ដោះអាសន្ន នូវ ការអនុវត្តន៍ សាលក្រមលេខ ០២.៩១ - ដ.ផ.ត.ប្រ.ក របស់តុលាការកំពូល ដែលមានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ :

១ - ផ្អាកជាបណ្ដោះអាសន្ននូវការអនុវត្តន៍ សាលក្រមរដ្ឋប្បវេណីលេខ ១៣៣ ចុះថ្ងៃទី ០៥- ៩- ៩១ របស់ តុលាការក្រុងភ្នំពេញដោយហេតុថា : តុលាការប្រជាជនកំពូល ពុំទាន់បានត្រួតពិនិត្យរឿងនេះហើយនៅឡើយ ។
២ - កម្មាភិបាល តុលាការប្រជាជន ទទួលបន្ទុកអនុវត្តសាលក្រម និង ជនដែលមាន

ផលប្រយោជន៍ក្នុងរឿងនេះ មានភារកិច្ចអនុវត្តតាមដីកានេះ ។

បានឃើញ សេចក្តីសំរេចលេខ ០៦.៩២ ម.ម.រ ចុះថ្ងៃទី០៦ ខែមិនា ឆ្នាំ១៩៩២ របស់ក្រុមប្រឹក្សាចៅក្រម តុលាការប្រជាជនកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

ប្រការ ១ : លប់ព្រមទាំងស្រុងតាមបណ្តឹងសារទុក្ខលេខ ០៥.៩២ ស.ស.រ កប្រក ចុះថ្ងៃទី ២១-២-៩២ របស់ប្រធាន តុលាការប្រជាជនកំពូល លើសាលក្រមរដ្ឋប្បវេណីលេខ ១៣៣ ចុះថ្ងៃទី ០៥-៨-៩១ របស់ តុលាការប្រជាជនក្រុងភ្នំពេញ ដែលមានកំហុសដូចខាងក្រោម :

តុលាការមិនបានអនុវត្តតាមអនុក្រឹត្យលេខ ២៥ អ.ន.ក្រ ចុះថ្ងៃទី ២២-០៤-៨៩ ត្រង់មាត្រា ២ ។

ប្រការ ២ : ណែនាំតុលាការប្រជាជនក្រុងភ្នំពេញត្រង់ចំណុច :

- អោយអនុវត្តតាមអនុក្រឹត្យលេខ ២៥ អ.ន.ក្រ ចុះថ្ងៃទី ២២-៤-៨៩ ត្រង់មាត្រា ២ ដោយអោយ ឈួន វណ្ណា ចេញគោលនយោបាយជាចំនួនទឹកប្រាក់ស្មើនឹងពាក់កណ្តាលនៃថ្លៃដី និង ផ្ទះដែល ឈួន វណ្ណា ស្នាក់នៅតាមការវាយតំលៃរបស់គណៈកម្មាធិការប្រជាជនក្រុងភ្នំពេញ ។

- ប្រគល់ ទ្យូន៍ និង ដី ដែលស្មើនឹងទីផ្ទះ ឈួន វណ្ណា ស្នាក់នៅ ទាំងខាងមុខ និង ទាំងខាងក្រោយអោយទៅ ឈួន វណ្ណា ។

ប្រការ ៣ : បញ្ជូន សំណុំរឿងរដ្ឋប្បវេណីលេខ ៣៨០ ចុះថ្ងៃទី ២៣-១០-៨៩ របស់ តុលាការប្រជាជនក្រុងភ្នំពេញ ទៅតុលាការសាមីដើម្បី ជំនុំជំរះ ឡើងវិញ ។

ប្រការ ៤ : សេចក្តីសំរេចនេះមានប្រសិទ្ធិភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១២១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩២ របស់ តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ទទួលសេចក្តីសំរេចរបស់ក្រុមប្រឹក្សាចៅក្រម តុលាការប្រជាជនកំពូល លេខ ០៦.៩២ ឈសរ ចុះថ្ងៃទី០៦ ខែមិនា ឆ្នាំ១៩៩២ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែត្រូវបដិសេធចោលនៅផ្នែកអង្គនិងគតិច្បាប់ ។

២ - តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៣៣ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ១៩៩១ របស់ តុលាការប្រជាជនក្រុងភ្នំពេញទុកជាបានការពេញទាំងមូល ដោយតម្រូវអោយឈ្មោះ ឈួន វណ្ណា ព្រមទាំងក្រុមគ្រួសារ រុះរើឥវ៉ាន់ចេញពីផ្ទះលេខ ១០៤ ផ្លូវ ២៨៦ ក្រុម ៤៣ សង្កាត់ទួលស្វាយព្រៃទី ២ ខណ្ឌចំការមន ក្រុងភ្នំពេញ ក្នុងរយះពេល ១០ "ដប់" ថ្ងៃ គិតចាប់តាំងពីថ្ងៃប្រកាស សាលក្រមនេះតទៅ ។

៣ - សាលក្រមនេះប្រកាសជា សាធារណៈ ចំពោះមុខគូក្តី សំរេចសារឡើងវិញ ជាលើកទី ១ និង ជាលើកចុងក្រោយបង្អស់ ។

បានឃើញ ដីកាផ្អាកការអនុវត្តន៍សាលក្រមជាបណ្តោះអាសន្ន លេខ ៣៣.៩២ ដជ.- តប្រក របស់ តុលាការប្រជាជនកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ផ្អាកការអនុវត្តន៍សាលក្រមរដ្ឋប្បវេណីលេខ ១២១ ចុះថ្ងៃទី ២៤- ៦- ៩២ របស់ តុលាការប្រជាជនក្រុងភ្នំពេញ ជាបណ្ដោះអាសន្ន ដោយមូលហេតុ :

តុលាការប្រជាជនក្រុងភ្នំពេញ ជំនុំជំរះ សាររឿងវិញនេះ គឺ ខុស នឹងសេចក្តីសំរេចលេខ ០៩- ៩២ ស.ស.រ ចុះថ្ងៃទី ០៩- ៣- ៩២ របស់ក្រុមប្រឹក្សាចៅក្រម តុលាការប្រជាជនកំពូល ។

២ - តុលាការប្រជាជនក្រុងភ្នំពេញ កម្មាភិបាលទទួលបន្ទុកអនុវត្តសាលក្រម និង ជនដែលមានប្រយោជន៍ក្នុងរឿងនេះ មានភារកិច្ចអនុវត្តតាមដីកានេះ ។

បានឃើញ ពាក្យបណ្តឹងតវ៉ាចុះថ្ងៃទី ២៤- ០៦- ៩២ របស់ឈ្មោះ ឈួន វណ្ណា មក - តុលាការប្រជាជនកំពូល តែ តុលាការកំពូល បានបញ្ជូនសំណុំរឿងទាំងមូលទៅ សាលាឧទ្ធរណ៍ ដើម្បី ជំនុំជំរះ បានតាមមាត្រា ២៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

បានឃើញ សាលដីកាឧទ្ធរណ៍លេខ ៧៤ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៤ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - សម្រេចថា សាលាឧទ្ធរណ៍ គ្មានសមត្ថកិច្ច ជំនុំជំរះ រឿងនេះទេ ហើយ បញ្ជូនរឿងនេះទៅ តុលាការកំពូល ជាសមត្ថកិច្ច ជំនុំជំរះ ។

២ - រីឯប្រាក់ប្រដាប់ក្តីដែលឈ្មោះ ឈួន វណ្ណា បានបង់រួចហើយ គឺ ពន្ធហ៊ីង និង ពន្ធចុះបញ្ជីក្តី ២.៥៥០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛០០ ចំណាយលើដីការកោះ ៥.០០០៛០០ និង ចំណាយលើអាជ្ញាករ តុលាការ ៥.០០០៛០០ សរុប ១៣.០០០៛០០ ។

៣ - សាលដីកានេះសំរេចចំពោះមុខក្តី ។

បានឃើញបណ្តឹងតវ៉ាជាលើកទី ២ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩២ របស់ឈ្មោះ - ឈួន វណ្ណា ត្រូវទៀងក្នុងកំណត់ច្បាប់ ។

បានឃើញ សារណារបស់ឈ្មោះ ឈួន វណ្ណា ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៩៥

បានឃើញ សារណារបស់ឈ្មោះ កោះ ស៊ីវ៉ាត ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៥

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ :

សាលក្រមរដ្ឋប្បវេណីលេខ ១២១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩២ របស់ តុលាការ ក្រុងភ្នំពេញ បានសំរេចត្រឹមត្រូវតាមច្បាប់ហើយ សូមក្រុមប្រឹក្សា ជំនុំជំរះ សំរេច- តាមច្បាប់ ។

លោក ឈួន វណ្ណា បានឆ្លើយថា ព្រោះ តុលាការថ្នាក់ក្រោមសំរេចសេចក្តីយក ដោយអយុត្តិធម៌ គឺអោយខ្លួនរុះរើផ្ទះចេញ ដោយមិនសមហេតុសមផលឡើយ ។ នៅពេលនោះ លោក កោះ ស៊ីវ៉ាត ហៅខ្លួនមកនៅគ្រាន់បានជាគ្នា ហើយគាត់អោយខ្លួនសង់ផ្ទះប្រកដំបូល ហើយជួរប្រកអោយគាត់ផង និង យកជញ្ជាំងផ្ទះរបស់គាត់ធ្វើជាជញ្ជាំងផ្ទះរបស់ខ្លួនទៅ ដល់ ក្រោយមកខ្លួនក៏យកផ្ទះនេះធ្វើជាសហករណ៍ផលិតនំ ដោយមានការយល់ព្រមពីគាត់ដែរ ។

លោក កោះ សុីវ៉ាត បានថ្លែងថា ខ្លួនមកកាន់កាប់តាំងពីឆ្នាំ ១៩៧៩ មកដល់ចុងឆ្នាំ ៨៤ ទើបលោក យួន វណ្ណា មកទ្រឹសបង្ខំ ដល់ចុងឆ្នាំ១៩៨៤ ខ្លួនបានគិតថ្លៃឈ្នួលដោយនិយាយថា ៣ឆ្នាំម្តង ទើបមានការទូទាត់គ្នាម្តង ដល់ផុតកិច្ចសន្យាគេនៅតែមិនរុះរើចេញទៀត ខ្លួនក៏ដាក់ពាក្យទៅ តុលាការដោះស្រាយ ដោយបានចេញថា សាលក្រម រួចតុលាការក្រុងបញ្ជូនទៅ តុលាការកំពូល ឯតុលាការកំពូល បានបញ្ជូន ទៅតុលាការក្រុងវិញ តុលាការក្រុងក៏តម្កល់ សាលក្រមមុនទុកជាបានការដដែល ឲ្យខ្លួនសុំសំណងការ សុំថ្លៃឈ្នួល និង ជម្ងឺចិត្ត ៥.០០០រៀល ។

ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរាយការណ៍
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់គូភាគី
ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងតវ៉ាសាលើកទី ២ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩២ របស់លោក យួន វណ្ណា ប្តឹងពី សាលក្រមលេខ ១២១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩២ របស់ តុលាការក្រុងភ្នំពេញ ដែល ជំនុំជំរះ ជាថ្មីឡើងវិញ ត្រូវឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមក ជំនុំជំរះ រួមក្រុមដល់អង្គសេចក្តីបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ២២៦ នៃច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា ការដែល តុលាការក្រុងភ្នំពេញ ជំនុំជំរះ ជាថ្មីឡើងវិញសំរេចតម្កល់ សាលក្រមរដ្ឋប្បវេណីលេខ ១៣៣ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ១៩៩១ របស់តុលាការក្រុងភ្នំពេញ ដែលត្រូវបានក្រុមប្រឹក្សាចៅក្រម តុលាការកំពូល ទុកជាមោឃៈហើយនោះ គឺជាការខុសឆ្គងនឹងទំរង់ច្បាប់ ។ ក្នុងករណីដែល តុលាការក្រុងភ្នំពេញ យល់ថាសាលក្រមនោះមានលក្ខណៈត្រឹមត្រូវក៏គួរតែបើសំរេចជាថ្មីឡើងវិញដែរ ។

- យល់ឃើញថា ការដែល សាលាឧទ្ធរណ៍ សំរេចថាគ្មានសមត្ថកិច្ច ជំនុំជំរះ រឿងនេះទេ ហើយបញ្ជូលសំណុំរឿងនេះទៅតុលាការកំពូល ជាសមត្ថកិច្ច ជំនុំជំរះ នោះដោយហេតុថាតុលាការក្រុងភ្នំពេញ បាន ជំនុំជំរះ សាឡើងវិញរួចហើយកាត់អំណាច សាលក្រមលេខ ១២១ ចុះថ្ងៃទី ២៤-៦-៩២ នៅចំពោះមុខគូក្តីលើកទី ១ និង ជាលើកចុងក្រោយដែរ ជាសាលក្រមមានអានុភាពអនុវត្ត ។ សាលក្រមនេះត្រូវបានប្តឹងតវ៉ាមក តុលាការកំពូល ជាថ្មីទៀត ប្រធាន តុលាការកំពូល ក៏ចេញដីកាផ្អាកការអនុវត្តន៍សាលក្រមនេះទៀតដែរ ដោយត្រៀមលក្ខណៈ ជំនុំជំរះ ផ្ទាល់ជាចុងក្រោយបង្អស់ ។ ប៉ុន្តែ តុលាការកំពូល មិនទាន់បាន ជំនុំជំរះ នៅឡើយ ក្នុងពេលនោះច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ត្រូវប្រកាសឲ្យប្រើ តុលាការកំពូល បញ្ជូនសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ ជំនុំជំរះ វិញ ។

- យល់ឃើញថា ការដែល តុលាការក្រុងភ្នំពេញសំរេចប្រគល់ មូលដ្ឋានសិប្បកម្មផលិតនំនៅផ្ទះលេខ ១០៤ ក្រុម ៤៣ សង្កាត់ទួលស្វាយព្រៃ ២ ខណ្ឌចំការមន ក្រុងភ្នំពេញ អោយទៅ កោះ សុីវ៉ាត កាន់កាប់ និង អោយ យួន វណ្ណា រុះរើសម្ភារៈចុះចេញពីផ្ទះកើតហេតុនោះជាការត្រឹមត្រូវពីព្រោះថា សេចក្តីសំរេចលេខ ០៩.៩២ ស.ស.រ ចុះថ្ងៃទី ០៩-៣-៩២

របស់ក្រុមប្រឹក្សាចៅក្រមតុលាការកំពូល បានណែនាំអោយ តុលាការក្រុងភ្នំពេញ អោយអនុវត្តតាមអនុក្រឹត្យលេខ ២៥ អ.ន.ក្រ ចុះថ្ងៃទី ២២-៥-៨៩ ត្រង់មាត្រា ២ ដោយអោយ ឈួន វណ្ណា ចេញគោលនយោបាយ ចំនួនទឹកប្រាក់ស្មើនឹងពាក់កណ្តាលនៃថ្លៃដី និង ផ្ទះដែល ឈួន វណ្ណា ស្នាក់នៅតាមការវាយតំលៃរបស់ គណកម្មាធិការក្រុងភ្នំពេញ ។

- យល់ឃើញថា ការដែលលោក កោះ ស៊ីវ៉ាត សុំទាមទារយកទ្បន់ និង ជម្ងឺចិត្ត នោះ តុលាការកំពូល ពុំមានសមត្ថកិច្ចពិចារណាឡើយ ពីព្រោះជាសំណូមពរថ្មី ។

- យល់ឃើញថា សាលក្រមលេខ ១២១ ចុះថ្ងៃទី ២៤-៦-៩២ របស់ តុលាការក្រុងភ្នំពេញ ដែលសំរេចជាថ្មីឡើងវិញនោះ មានការខុសឆ្គងទាំងទំរង់ និង គតិច្បាប់ ។

ហេតុនេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខក្តី

១ - ទទួលបណ្តឹងតវ៉ាសារលើកទី ២ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩២ របស់លោក ឈួន វណ្ណា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈសាលក្រមរដ្ឋប្បវេណីលេខ ១២១ ចុះថ្ងៃទី ២៤-៦-៩២ របស់ តុលាការក្រុងភ្នំពេញទាំងមូល ។

៣ - ប្រគល់ទ្បន់ និង ដី ដែលស្មើនឹងទទឹងផ្ទះ ឈួន វណ្ណា ស្នាក់នៅទាំងខាងមុខ និង ទាំងខាងក្រោយអោយទៅ ឈួន វណ្ណា តាមមាត្រា ២ អនុក្រឹត្យលេខ ២៥ អ.ន.ក្រ ចុះថ្ងៃទី ២២-៥-៨៩ ។ ប៉ុន្តែអោយ ឈួន វណ្ណា ចេញគោលនយោបាយ ចំនួនទឹកប្រាក់ស្មើនឹងពាក់កណ្តាលនៃថ្លៃដីដែល ឈួន វណ្ណា ស្នាក់នៅអោយទៅ កោះ ស៊ីវ៉ាត ។ សំណូមពរលើសពីនេះ ត្រូវបដិសេធចោល ។

៤ - រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛០០ ដែលលោក ឈួន វណ្ណា បានបង់រួចហើយ គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៤.០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛០០ សម្រាប់សារង្វាន់ក្រឡាបញ្ជីការហិបប្រាក់ ,

- ចំណាយលើកិច្ចប្រគល់ដីការកោះ ចំនួន ១៥.០០០៛០០ សរុប ១៩.០០០៛០០ ហើយត្រូវអោយលោក កោះ ស៊ីវ៉ាត សងប្រាក់ចំនួន ១៩.០០០៛០០ នេះទៅលោក ឈួន វណ្ណា វិញ ។

- បង្គាប់អោយលោក ឈួន វណ្ណា បង់ពន្ធសមាមាត្រ មួយភាគរយ លើទឹកប្រាក់ដែលត្រូវប្រគល់អោយលោក កោះ ស៊ីវ៉ាត និង អោយលោក កោះ ស៊ីវ៉ាត បង់ពន្ធសមាមាត្រ មួយភាគរយ លើតម្លៃដីស្មើនឹងពាក់កណ្តាលនៃដីដែល ឈួន វណ្ណា ស្នាក់នៅ ប្រាក់ពន្ធនេះដាក់ចូលថវិការដ្ឋ ៨០ ភាគរយ និង រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

៥ - សាលដីកានេះ ប្រកាសនា សវនាការ ជាសាធារណៈ នៅថ្ងៃទី ១៧ - ខែមិថុនា ឆ្នាំ១៩៩៩ ។